ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២៦ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១— ព្រះរាជក្រម

១៩.៧.១៩៩៥ – ព្រះរាជក្រម លេខ ០១ .ជ.ស ៩៥ ១១២៨

២— ព្រះរាជក្រឹត្យ

៣.៧.១៩៩៥ –ព្រះរាជក្រឹត្យ លេខ NS/KRT/0795/54 ១១២៩

៥.៧.១៩៩៥ – ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧៩៥ / ៥៥ ១១៣០

៨.៧.១៩៩៥ – ព្រះរាជក្រឹត្យ លេខ នស/រកត / ០៧៩៥ / ៥៧ ១១៣១

II- ទីស្ដីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

២០.៧.១៩៩៥ – អនុក្រឹត្យ លេខ ៥៧ អនក្រ.បក ស្ដីពីការបញ្ជូនពលករខ្មែរ
ទៅធ្វើការនៅបរទេស ១១៣២

២. សេចក្ដីសំរេច

១៧.៧.១៩៩៥ – សេចក្ដីសំរេច លេខ ៥០ សសរ ស្ដីពីការបង្កើតគណៈកម្មការ
ត្រួតពិនិត្យ និងដេញថ្លៃឈើនៅសេសសល់ក្រោយឱសានវាទ. ១១៣៨

២០.៧.១៩៩៥ – សេចក្ដីសំរេច លេខ ៥១/ សសរ ស្ដីពីការផ្ទេរយន្តហោះ បុគ្គលិក.
រោងជាង ឃ្លាំងសំភារៈ និង ឧបករណ៍ ស្ថិតក្រោមឱវាទទីស្ដីការ
គណៈរដ្ឋមន្ត្រី ១១៤១

២០.៧.១៩៩៥ – សេចក្តីសំរេច លេខ ៥២សសរ ស្តីពីការបង្កើតគណកម្មការចំរុះកម្ពុជា ម៉ាលេស៊ី សំរាប់កិច្ចសហប្រតិបត្តិការ សេដ្ឋកិច្ច វិទ្យាសាស្ត្រ និង បច្ចេកទេស ១១៤២

III-ការងារបណ្តាក្រសួង

១.ទីស្តីការ រដ្ឋមន្ត្រី ក្រសួងព័ត៌មាន

១៧.៧.១៩៩៥ – ប្រកាស លេខ ២៤៩/ ៩៥ ពម ប្រក ស្តីពីការយល់ព្រមអោយប្តូរ តំណែងពីលោក អ៊ិន ប៉ន ជូនមកលោក សៅ.សុគុន ជាចាងហ្វាង ទស្សនាវដ្តីសមាគមគ្រូពេទ្យកម្ពុជា .វិញ . ១១៤៥

១៩.៧.១៩៩៥ – ប្រកាស លេខ ១៥០/៩៥ ពម ប្រក ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ របស់មន្ត្រីរាជការ ១១៤៦

១៩.៧.១៩៩៥ – ប្រកាស លេខ ១៥១/ ៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះ មន្ត្រីរាជការ ចេញពីក្របខ័ណ្ឌក្រសួង ១១៤៧

១៩.៧.១៩៩៥ – ប្រកាស លេខ ១៥២/ ៩៥ ពម .ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជ ការចេញពីក្របខ័ណ្ឌក្រសួង ១១៤៨

១៧.៧.១៩៩៥ –ប្រកាស លេខ ១៥៣/ ៩៥ពម ប្រក ស្តីពីការយល់ព្រម មន្ត្រីរាជការ តាំងស៊ុបក្នុងក្របខ័ណ្ឌ ១១៤៩

១៧.៧.១៩៩៥ – ប្រកាសលេខ ១៥៤/ ៩៥ ពម.ប្រក ស្តីពី ការយល់ព្រម និង ទទួលស្គាល់មន្ត្រីរាជការ ១១៥០

១៩.៧.១៩៩៥ – ប្រកាស លេខ ១៥៥/ ៩៥ពម ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ចេញពីក្របខ័ណ្ឌក្រសួង ១១៥១

១៩.៧.១៩៩៥ – ប្រកាសលេខ ១៥៦/ ៩៥ ពម .ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ១១៥២

២ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

១៧.៧.១៩៩៥ – ប្រកាស លេខ ៥០០ ប្រក.មស.បល ស្តីពីការអនុញ្ញាតច្បាប់អោយ
ទំនេរគ្មានបៀវត្ស ១១៥៣

៣—រដ្ឋាករអាកាសចរស៊ីវិល

ប្រកាស

១៨.៧.១៩៩៥ – ប្រកាស លេខ ០៦៧៨. អ.អ.ស.ព.ក.៩៥ ស្តីពីការឈប់ផ្តល់
ប័ណ្ណ.និងផ្លាករថយន្តសំរាប់ចេញ .ចូលក្នុងអាកាសយានដ្ឋានអន្តរ
ជាតិពោធិចិនតុង ១១៥៤

៤.ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម
រ៉ែ និង ថាមពល

ប្រកាស

១៨.៧.១៩៩៥ – ប្រកាស លេខ ៥១៩ បល.ប្រក ស្តីពីការបង្កើតអង្គ ភាពទម្ងន់ និង
រង្វាស់រង្វាល់ ១១៥៥
១៨.៧.១៩៩៥ – ប្រកាស លេខ ៥២០ ផក.ប្រក អនុញ្ញាតឱយលោក ចេង .សេ
ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតទឹកត្រីកំពត «ផ្លូវហ៊្វូត» ១១៥៧
២១.៧.១៩៩៥ – ប្រកាស លេខ ៥៣៣ ផក.ប្រក អនុញ្ញាត ឱយ លោក សៀន ផា រ៉ូ
ដំណើរការសិប្បកម្មផលិតស្រាស សញ្ញា «ព្រះអាទិត្យ» ១១៥៧

៥. ទីស្តីការរដ្ឋមន្ត្រី ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

សេចក្តីសំរេច

១៧.៧.១៩៩៥ សេចក្តីសំរេច លេខ ៣៥៦ សសរ .កសក. ស្តីពីការពិសោធន៍ ស្ទូចកូនត្រីព្រាខ្មៅ ១១៥៨

៦. ទីស្តីការ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ :

ប្រកាស

១៨.៧.១៩៩៥ – ប្រកាស លេខ ១៣០ ប្រក.វវស.បុ ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ របស់មន្ត្រីរាជការ ១១៥៩

២០.៧.១៩៩៥ – ប្រកាស លេខ ១៣២ ប្រក.វវស.បុ ស្តីពីការបង្កើត គណកម្មការ និងអនុគណៈកម្មការប្រឡងបរិញ្ញាប័ត្រសិល្បៈតន្ត្រី ឆ្នាំ ១៩៩៤ .៩៥ ១១៦០

៧. ទីស្តីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

២១.៧.១៩៩៥ – ប្រកាស លេខ ២៥៩៣. អផប ស្តីពីការផ្ទេរបុគ្គលិក .មន្ត្រី រាជការ ១១៦២

៨ .ទីស្តីការ ក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

១៩.៧.១៩៩៥ – សេចក្តីសំរេច លេខ ១៤៨/ ៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់ទទួលស្គាល់អោយបើកកន្លែងថ្វាយបង្គំព្រះរបស់ក្រុមជំនុំ គ្រិស្ទានខ្មែរ ១១៦៤

១៩.៧.១៩៩៥ – សេចក្តីសំរេច លេខ ១៤៩/៩៥ កធស ស្តីពីការអនុញ្ញាតច្បាប់ ទទួលស្គាល់ព្រះវិហារ « សាសនាសង្គ្រោះ ព្រះនាងគង់ស៊ីអ៊ឹម » ១១៦៥

យោងអត្ថបទ		ខ្លឹមសារលិខិត	យោងសៀវភៅរាជកិច្ច		
លេខចំណងសញ្ញាលិខិត	ថ្ងៃខែឆ្នាំ		លេខ	ថ្ងៃខែឆ្នាំ ១៩៩៥	ទំព័រ
១៤៩/៩៥ពម. ប្រក	១៧.៧.៩៥	ប្រកាសលេខ១៤៩/៩៥ពម.ប្រក ស្តីពីការយល់ព្រមអោយប្តូរតំណែងពីលោក អ៊ុន ប៉ន ជូនមកលោក សៅ សុគខុន ជាចាងហ្វាងទស្សនាវដ្តីសមាគមគ្រូពេទ្យកម្ពុជាវិញ	២៦	២៣កក្កដា	១១៤៥
១៥០/៩៥ពម. ប្រក	១៩.៧.៩៥	ប្រកាសលេខ១៥០/៩៥ពម.ប្រក ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ	២៦	–	១១៤៦
១៥១/៩៥ពម. ប្រក	១៩.៧.៩៥	ប្រកាសលេខ១៥១/៩៥ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង	២៦	–	១១៤៧
១៥២/៩៥ពម. ប្រក	១៩.៧.៩៥	ប្រកាសលេខ១៥២/៩៥ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង	២៦	–	១១៤៨
១៥៣/៩៥ពម .ប្រក	១៧.៧.៩៥	ប្រកាសលេខ១៥៣/៩៥ពម.ប្រក ស្តីពីការយល់ព្រមមន្ត្រីរាជការតាំងស៊ុបក្នុងក្របខ័ណ្ឌ	២៦	–	១១៤៩
១៥៤/៩៥ពម. ប្រក	១៧.៧.៩៥	ប្រកាសលេខ១៥៤/៩៥ពម.ប្រក ស្តីពីការយល់ព្រមនិងទទួលស្គាល់មន្ត្រីរាជការ	២៦	–	១១៥០

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១—ព្រះរាជក្រម

ព្រះរាជក្រមលេខ ០១ ជស ៩៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៥ ស្តីពី ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមិត្តភាព និង សហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

ការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមិត្តភាព

និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍

មាត្រា ១ .– យល់ព្រមលើសន្ធិសញ្ញាមិត្តភាព និងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ ធ្វើនៅផិនប៉ាសាបាលី ប្រទេសឥណ្ឌូណេស៊ី កាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ដូចដែលមានអត្ថបទភ្ជាប់ជាមួយ ។

មាត្រា ២ .– រាជរដ្ឋាភិបាលកម្ពុជាត្រូវបន្តនីតិវិធី ក្រោយពីបានចុះហត្ថលេខា លើលិខិតបករណ៍នៃការចូលរួមក្នុងសន្ធិសញ្ញាខាងលើ ដើម្បីបញ្ចូលព្រះរាជាណាចក្រកម្ពុជាក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន ។

មាត្រា ៣ .– ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

KRET
(Palais Royal)
NS/KRT/0795/54

NOUS
NORODOM SIHANOUK
ROI DU CAMBODGE
ACCORDONS

le rang de Ministre-Conseiller à :

I/- Monsieur CHUM NGOEUN

II/- Monsieur UM EM

III/- Monsieur MEAK SAMPHUON

IV/- Monsieur KUY SOPHÂL

Fait le 3 Juillet 1995
sa Majesté a Siqné
NORODOM SIHANOUK

* * *

២—ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៥/៥៥

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលជាតិកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃ រាជរដ្ឋាភិបាលជាតិកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **តាន់ ស៊ុនឆូ** ជាអនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជវាំងភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៥

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៥/៥៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលជាតិកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃ រាជរដ្ឋាភិបាលជាតិកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងជាទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា នូវឥស្សរជន ដូចមានរាយនាមខាងក្រោម :

- អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ផាន់ដារាវង្ស** ទទួលបន្ទុកកិច្ចការទំនាក់ទំនងអន្តរជាតិមានឋានៈស្មើអនុរដ្ឋលេខាធិការ។

- ឯកឧត្តម **អ៊ុំ គឹមឡៀន** ទទួលបន្ទុកកិច្ចការទំនាក់ទំនងជាក្រសួងមហាផ្ទៃ មានឋានៈស្មើអនុ

រដ្ឋលេខាធិការ ។

- ឯកឧត្តម ខាំ សោភ័ណ ទទួលបន្ទុកកិច្ចការរដ្ឋបាលមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជវាំងជាក់, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II- ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

ភ្នំពេញ , ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

អនុក្រឹត្យ លេខ : ៥៧ អនក្រ.បក

ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៩៩ ក្រ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ**

ឧទ្ទិន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ឧទ្ទិន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន

សំរេច

មាត្រា ១ : ដើម្បីដោះស្រាយជីវភាព និង បង្កើនមុខជំនាញវិជ្ជាជីវៈ រាជរដ្ឋាភិបាលអនុញ្ញាតអោយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសនៅពេលដែលទីផ្សារ ការងារក្នុងប្រទេសមិនទាន់មានលទ្ធភាពទទួលយកអ្នកគ្មានការងារធ្វើ និង អ្នកដែលមានការងារធ្វើមិនពេញលេញបានអស់ និង រកប្រាក់ចំណូលចូលថវិកាជាតិ ។

មាត្រា ២ : ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និង ការគ្រប់គ្រងពលករទាំងនេះជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនអាចអនុញ្ញាតតាមប្រកាសរបស់ក្រសួងអោយក្រុមហ៊ុនណាមួយបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសបាន ។

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ត្រូវចេញសារាចរណែនាំអនុវត្តបន្ថែម ទៀតក្នុងករណីចាំបាច់ ។

ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ត្រូវសហការជាមួយក្រសួងមហាផ្ទៃក្នុងការធ្វើទំរង់បែបបទដូចជាលិខិតឆ្លងដែនជាដើម ដើម្បីបញ្ជូនពលករទៅបរទេស ហើយត្រូវសហជាមួយក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្នុងការគ្រប់គ្រងពលករ ខ្មែរដែលធ្វើការនៅបរទេស ។

មាត្រា ៣ : ត្រូវបានចាត់ទុកជាបេក្ខជនសំរាប់ជ្រើសរើសបញ្ជូនអោយទៅធ្វើការនៅបរទេស ពលករខ្មែរ ទាំងពីរភេទមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលបានដាក់ពាក្យសុំរកការងារធ្វើនៅក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

មាត្រា ៤ : ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ហៅថាភាគីផ្តល់ពលករ ។
ក្រុមហ៊ុនដែលស្នើសុំជ្រើសរើសពលករ ហៅថាភាគីទទួលពលករ ។

មាត្រា ៥ : រាល់សំណើពីភាគីទទួលពលករ ត្រូវបញ្ជាក់អោយច្បាស់លាស់អំពីល័ក្ខខ័ណ្ឌសំខាន់ ៗ ជាអាទិ៍ :

- កាលបរិច្ឆេទចាប់ផ្តើមអនុវត្ត និង បញ្ចប់ការងារ
- ប្រភេទការងារ
- ទីកន្លែងទៅធ្វើការងារ
- ចំនួន និង មុខជំនាញរបស់ពលករ
- ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេង ៗ ដោយគិតទាំងការស្នាក់នៅ ហូបចុក ស្លៀកពាក់ព្យាបាល ព្រមទាំងបញ្ហាផ្សេង ៗ ទៀតក្នុងជីវភាពប្រចាំថ្ងៃ
- ការដឹកជញ្ជូនពលករទៅ និង មក ។

ក្រោយពីបានទទួលសំណើ ភាគីផ្តល់ពលករត្រូវឆ្លើយទៅភាគីទទួលពលករវិញយ៉ាងយូរបំផុត ៤៥ ថ្ងៃដោយត្រូវបញ្ជាក់ថា តើអាចផ្តល់ពលករបានកំរិតណា ឬ មិនបាន ឬ ត្រូវពិភាក្សាគ្នាបន្ថែមទៀត ។

ភាគីទទួលពលករ ត្រូវឆ្លើយមកភាគីផ្តល់ពលករវិញយ៉ាងយូរ ៣០ ថ្ងៃ ថាតើត្រូវការពលករ ទាំងអស់នោះឬទេ ឬត្រូវការតែកំរិតណាមួយនោះដោយត្រូវចូលមកពិភាក្សានៅពេលជាមួយគ្នានេះដែរ។ ហួសរយៈពេល ៣០ ថ្ងៃ ហើយបើគ្មានចម្លើយ និង មិនឃើញចូលមកពិភាក្សា ទេភាគីផ្តល់ពលករកំណត់ថា ភាគីទទួលពលករមិនត្រូវការពលករទាំងនោះទេ ។

មាត្រា ៦ : ការបញ្ជូនពលករទៅបរទេសអាចអនុវត្តបាន លុះត្រាតែមានការអនុញ្ញាតពីភាគីផ្តល់ពលករ និងត្រូវមានកិច្ចសន្យាការងាររវាងពលករ ជាមួយភាគីទទួលពលករ ។

មាត្រា ៧ : ក្រោយពេលទទួលការអនុញ្ញាតជាផ្លូវការរយៈពេល ៧ ថ្ងៃ យ៉ាងយូរ ភាគីទទួលពលករត្រូវកក់ប្រាក់ធានាចំនួនមួយរយពាន់ដុល្លារអាមេរិកនៅក្នុងគណនីរបស់ភាគីផ្តល់ពលករ ។

បើភាគីទទួលពលករមិនបានបង់ប្រាក់ធានានេះទេ ការអនុញ្ញាតនេះនឹងត្រូវចាត់ទុកជាមោឃៈ ។

ប្រាក់តំកល់នេះ សំរាប់អោយភាគីផ្តល់ពលករបើកអោយពលករ ជំនួសភាគីទទួលពលករក្នុងករណីដែលភាគីនេះ មិនបានគោរពលក្ខខ័ណ្ឌណាមួយដែលមានចែងក្នុងកិច្ចសន្យាការងារ ។

ក្នុងពេលអនុវត្តកិច្ចសន្យាការងារ បើប្រាក់តំកល់នេះត្រូវបានដកខ្លះ ដើម្បី អោយពលករភាគីទទួលពលករត្រូវបង់បំពេញអោយ បានគ្រប់ចំនួនឡើងវិញ។

ភាគីទទួលពលករអាចដកប្រាក់តំកល់នេះទេវិញបាននៅពេលចប់កិច្ចសន្យាការងារជាស្ថាពរជាមួយពលករទាំងអស់ ។

ប្រាក់តំកល់ក្នុងមាត្រានេះ អាចបន្ធូរបន្ថយបានចំពោះនិយោជកដែលត្រូវការជ្រើសរើសពលករខ្មែរ តែបន្តិចបន្តួចដោយផ្ទាល់ ដើម្បីយក ទៅធ្វើការក្នុងរោងជាង ឬ រោងសិប្បកម្មរបស់ខ្លួន ។ ប៉ុន្តែនិយោជកនោះ ចាំបាច់ត្រូវពិភាក្សាជាមួយក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ដើម្បីធ្វើកិច្ចសន្យាឯកត្តភូតជាមួយពលករទាំងនោះ ។

មាត្រា ៨ : ភាគីទទួលពលករត្រូវបង់សោហ៊ុយសេវា និង ការរៀបចំឯកសារផ្សេង ៗ ជូនភាគីផ្តល់ពលករតាមការឯកភាពគ្នាដែលមានកំណត់ក្នុងកិច្ចសន្យា ។

មាត្រា ៩ : កិច្ចសន្យាការងារ ត្រូវបញ្ជាក់អោយច្បាស់ជាអាទិ ÷

- ឈ្មោះ និង អាសយដ្ឋានរបស់ភាគីនិមួយ ៗ
- កាលបរិច្ឆេទនៃការចាប់ផ្តើម និង បញ្ចប់កិច្ចសន្យា
- ទីកន្លែង និង ប្រភេទការងារជាក់ស្តែង
- [illegible]ញពលករ
- ប្រាក់ឈ្នួល និង ប្រាក់បំណាច់ផ្សេង ៗ
- ភាគឈ្នួល និង ប្រាក់បំណាច់ផ្សេង ៗ ដែលត្រូវបញ្ជូនមកគ្រួសារ
- ពេលម៉ោងធ្វើការ និង ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ប្រចាំឆ្នាំ
- ការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល
- ការបង់ប្រាក់ធានារ៉ាប់រងចំពោះពលករម្នាក់ ៗ
- ការប្រគល់ និង ទទួលពលករពេលទៅ និង ពេលត្រឡប់មកវិញ
- សោហ៊ុយដឹកជញ្ជូនពលករទៅ និង មក

– ករណីដែលត្រូវបញ្ជូនពលករមកមាតុប្រទេសវិញមុនកាលកំណត់ក្នុងកិច្ចសន្យាការងារ។

មាត្រា១០ : ពលករទាំងអស់ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួល ដែលភាគីទទួលពលករត្រូវចេញអោយ ។ ឯចំនួនថ្ងៃឈប់សំរាកនេះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះយ៉ាងតិចក្នុងរយៈពេលធ្វើការមួយខែជាប់ ។

មាត្រា១១ : កិច្ចសន្យាការងារ ត្រូវធ្វើជាពីរភាសាដែលមានតំលៃស្មើគ្នា គឺ ភាសាខ្មែរ និង ភាសាបារាំងឬ អង់គ្លេស ។ រយៈពេលនៃកិច្ចសន្យាការងារមិនត្រូវអោយលើសពីរឆ្នាំឡើយ ។

នៅពេលចប់អាណត្តិនៃកិច្ចសន្យាការងារ ភាគីទាំងពីរអាចពិភាក្សាគ្នាបន្តអនុវត្តកិច្ចសន្យាទៅទៀតបាន ឬ មួយធ្វើកិច្ចសន្យាសាថ្មី ។ កិច្ចសន្យាបន្តការងារតទៅទៀត ឬ ធ្វើ សាជាថ្មីក៏ត្រូវមានការចុះទិដ្ឋាការសាថ្មីពីក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនដែរ។

មាត្រា១២ : ភាគីផ្តល់ពលករ ជាអ្នកជ្រើសរើសពលករតាមមុខជំនាញនីមួយ ។ អោយបានគ្រប់ចំនួនដែលបានកំណត់ក្នុងកិច្ចសន្យាការងារ ។

កិច្ចសន្យាការងារ ដែលពលករចុះហត្ថលេខាជាមួយភាគីទទួលពលករត្រូវមានចុះទិដ្ឋាការរបស់អធិការការងារមានសមត្ថកិច្ច ។

មាត្រា១៣ : នៅពេលចុះកិច្ចសន្យាការងារ ពលករម្នាក់ ។ ត្រូវផ្តល់ ÷

- –ជីវប្រវត្តិសង្ខេបរបស់សាមីជនមានបិទរូបថត ៤ × ៦ សម ២ សន្លឹក
- –សំបុត្រថ្កោលទោស ២ ច្បាប់
- –លិខិតបញ្ជាក់សុខភាព ដែលចេញអោយដោយនាយកដ្ឋានពេទ្យការងារ ២ ច្បាប់
- –សេចក្តីចម្លងសញ្ញាប័ត្រ ឬ លិខិតបញ្ជាក់មុខជំនាញ « ប្រសិនជាមាន » ២ ច្បាប់
- –សេចក្តីចម្លងលិខិតឆ្លងដែនរបស់សាមីជន ២ ច្បាប់
- –ប័ណ្ណសុំការងារ ១ ច្បាប់

មាត្រា១៤ : មុនពេលចេញដំណើរទៅប្រទេសភាគីផ្តល់ពលករ និង ទទួលពលករ ត្រូវទទួលបន្ទុករៀបចំធ្វើកម្មសិក្សាអំពីរបៀបរបបធ្វើការងាររបៀបរបបរស់នៅទំនៀមទំលាប់ប្រពៃណី និង ច្បាប់ទំលាប់ជាចាំបាច់របស់ប្រទេសទទួលពលករ ។

មាត្រា១៥ : ប្រាក់បៀវត្សរបស់ពលករម្នាក់ ។ ត្រូវជាប់ពន្ធតាមច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា១៦ : ភាគីទទួលពលករ ត្រូវរ៉ាប់រងចេញសោហ៊ុយចំណាយ អោយមន្ត្រីរបស់ប្រទេសផ្តល់ពលករទៅបំពេញបេសកកម្ម ដើម្បីជូនពលករទៅដល់ប្រទេសទទួលពលករ ត្រួតពិនិត្យលក្ខខណ្ឌការងារ ទីកន្លែងធ្វើការងារ និង ទីស្នាក់អាស្រ័យរបស់ពលករដែលបានកំណត់ក្នុងកិច្ចសន្យា ។

ភាគីផ្តល់ពលករ ត្រូវបញ្ជូនមន្ត្រីទៅពិនិត្យការ អនុវត្តន៍កិច្ចសន្យាការងារដល់ទីកន្លែងក្នុងរយៈពេលដែលចាំបាច់ ។

មាត្រា១៧ : បើមានវិវាទការងារកើតឡើង ភាគីទទួលពលករត្រូវពិភាក្សា និង ដោះស្រាយជាមួយពលករភ្លាម ដោយផ្អែកទៅលើកិច្ចសន្យាការងារ ។ បើការពិភាក្សាគ្នានេះមិនអាចសំរុះសំរួលគ្នាបានទេនោះ គេត្រូវផ្តល់ពត៌មានភ្លាមទៅស្ថានឯកអគ្គរាជទូត ឬ បេសកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ដើម្បីចូលរួមដោះស្រាយ ។

មាត្រា១៨ : ភាគីទទួលពលករ ត្រូវផ្តល់ពត៌មានដល់ភាគីផ្តល់ពលករអោយបាន ៤៥ ថ្ងៃមុនកាលបរិច្ឆេទនៃការវិលត្រឡប់មកមាតុប្រទេសវិញពិតប្រាកដរបស់ពលករ ។

ភាគីទទួលពលករ និង ភាគីផ្តល់ពលករត្រូវរៀបចំរួមគ្នាអំពីប្រតិទិននៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ។

មាត្រា១៩ : ការបាត់ខ្លួនរបស់ពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ភាគីទទួលពលករត្រូវផ្តល់ពត៌មានជាបន្ទាន់ដល់ស្ថានឯកអគ្គរាជទូត ឬ បេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ និង មកក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២០ : ជនណាដែលបញ្ជូនពលករខ្មែរ ទៅធ្វើការនៅបរទេសដោយល្មើសនឹងបទបញ្ញត្តិទាំងឡាយក្នុងអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា២១ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា២២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនត្រូវ អនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២—សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ ៥០ សសរ

ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យ និង

ដេញថ្លៃឈើដែលនៅសេសសល់ក្រោយឱសានថាន

* * *

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា .

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .

– តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការត្រួតពិនិត្យ និង ដាក់អោយដេញថ្លៃឈើនៅសេសសល់ក្រោយឱសានវាទ ដែលមានសមាសភាពដូចតទៅ ៖

- ឯកឧត្តម **តាវ សេងហួរ** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ប្រធាន
- ឯកឧត្តមឧត្តមសេនីយ៍ឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការក្រសួងការពារជាតិ អនុប្រធាន
- ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក
- ឯកឧត្តម **អ៊ុម ឈុនលឹម** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
- ឯកឧត្តម **ម៉ុន អ៊ុយ** អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក
- ឯកឧត្តម **ខាំ ម៉េងឈាង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

ប្រការ ២ : ដោយប្រធានគណៈកម្មការនេះ ជារដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគណៈកម្មការនេះ មានភារកិច្ចអនុវត្តនូវសមត្ថកិច្ច និង ភារកិច្ច ដែលចែងក្នុងក្រឹត្យច្បាប់លេខ ៣៥ ក្រច. ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ។
លើសពីនេះទៅទៀត គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម ៖

- ត្រួតពិនិត្យការអនុវត្តន៍សេចក្ដីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០៣ ប្រក ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥ ស្ដីពីនយោបាយព្រៃឈើ ។
- ជំរឿនស្ថិតិ និង ត្រួតពិនិត្យឈើដែលបានកាប់ឆ្លលំរំលំ ហើយនៅសេសសល់ទូទាំងព្រះរាជាណាចក្រកម្ពុជាក្រោយឱសានវាទ ដោយធ្វើការវាស់វែងនិងបែងចែកអោយបានច្បាស់លាស់ អំពីបរិមាណឈើដែលមានច្បាប់ និង បរិមាណឈើដែលគ្មានច្បាប់ ។
- ធ្វើការណែនាំច្បាស់លាស់ ចំពោះឈើស្របច្បាប់ ដែលនៅសេសសល់ពីការនាំចេញ ។
- ចាត់វិធានការច្បាស់លាស់ ចំពោះសំភារៈ បរិក្ខារ សំរាប់ធ្វើអាជីវកម្មឈើដែលនៅសេសសល់ក្នុងព្រៃ ។

-លើកយោបល់អំពីមុខសញ្ញា ដែលត្រូវចាត់ចែងឈើនោះ ដើម្បីសុំការសំរេចពីរាជរដ្ឋាភិបាល ។

-រៀបចំបែបបទ និង នីតិវិធីដេញថ្លៃ សំរាប់អនុវត្តក្នុងការលក់ឈើដែលបានសំរេចរឹបអូសហើយ ដើម្បីប្រើប្រាស់ក្នុងស្រុក ។

-ប្រកាសលក់អោយដេញថ្លៃជាសាធារណៈ ចំពោះឈើដែលតុលាការបានសំរេចរឹបអូសដាក់ជាសម្បត្តិរដ្ឋ ។

-បង់ចូលថវិការដ្ឋអោយបានគ្រប់ចំនួន និង ទាន់ពេលវេលានូវបរិមាណប្រាក់ដែលបានមកពីការលក់ឈើដេញថ្លៃ ។

ប្រការ ៣ : គណៈកម្មការនេះ មានក្រុមជំនួយការ ដើម្បីជួយធ្វើការងាររបស់ខ្លួនដែលមានសមាសភាពដូចខាងក្រោម ÷

-លោក **ចំនួ សារុន** ប្រធាននាយកដ្ឋាន រុក្ខាប្រមាញ់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ប្រធាន

-លោកឧត្តមសេនីយ៍ទោ **លី សេងហុង** នាយរងអគ្គសេនាធិការក្រសួងការពារជាតិ អនុប្រធាន

-លោកឧត្តមសេនីយ៍ទោ **មល់ រឿម** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

-លោកឧត្តមសេនីយ៍ទោ **នុំ សម្បុរ** ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ សមាជិក

-លោកឧត្តមសេនីយ៍ **ម៉ៅ ច័ន្ទតារា** អនុប្រធានទី ១ នាយកដ្ឋានកណ្តាលយុត្តិធម៌ ក្រសួងមហាផ្ទៃ សមាជិក

-លោក **ម៉ុល អួន** អនុប្រធាននាយកដ្ឋានទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

-លោក **អេង ម៉ិនហួរ** អនុប្រធានការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

-លោក **ជួន ចន** អនុប្រធានការិយាល័យ នាំចេញនាំចូល ក្រសួងពាណិជ្ជកម្ម សមាជិក

-លោក **ស៊ុំ សុខុន** តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

-លោក **សរ ស៊ុយអ៊ុន** តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

-លោក **ផាល់ ចំនួនសារា** ក្រុមប្រឹក្សាបញ្ជីនៃទីស្តីការរាជរដ្ឋាភិបាល សមាជិក

ប្រការ ៤ : គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

ប្រការ ៥ : សមាជិកទាំងអស់នៃគណៈកម្មការ និង ក្រុមជំនួយការ ត្រូវចូលរួមប្រជុំតាម សេចក្តីអញ្ជើញរបស់ប្រធាន ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនិង ឯកឧត្តមអស់លោកដែលមានឈ្មោះក្នុងប្រការ ១ និងប្រការ ៣ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៥១ សសរ

ស្តីពីការផ្ទេរ យន្តហោះ បុគ្គលិក ពេទចាង ឃ្លាំងសំភារៈ និងឧបករណ៍សំភារៈស្តុកក្រោមឱវាទទីស្តីការគណៈរដ្ឋមន្ត្រី

* * *

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរបស់រាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- តាមតំរូវការជាក់ស្តែងក្នុងការដឹកជញ្ជូនភ្ញៀវកិត្តិយស

សំរេច

ប្រការ ១ : ផ្ទេរបុគ្គលិក យន្តហោះ រោងជាង ឃ្លាំងសំភារៈ និង ឧបករណ៍សំភារៈស្ថិតក្រោមនិភាពទីស្តីការគណៈរដ្ឋមន្ត្រី ដូចមាននៅក្នុងបញ្ជីដូនភ្ជាប់មកជាមួយ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រុមហ៊ុនអាកាសចរកម្ពុជា ត្រូវអនុវត្តតាមសេចក្តីសំរេចចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៥២ សសរ

ស្តីពីការបង្កើតគណៈកម្មការចំរុះកម្ពុជា_ម៉ាឡេស៊ី សំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វិទ្យាសាស្ត្រ និង បច្ចេកទេស

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ**នរោត្តមសីហនុ**

ទស្សនៈ ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សម្រេច

ប្រការ ១: បង្កើតគណៈកម្មការមួយមានឈ្មោះថា « គណៈកម្មការចំរុះកម្ពុជា_ម៉ាឡេស៊ី សំរាប់កិច្ចសហ ប្រតិបត្តិការសេដ្ឋកិច្ច វិទ្យាសាស្ត្រ និង បច្ចេកទេស ដែលមានសមាសភាពដូចតទៅ :

១_ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ប្រធាន
២_ឯកឧត្ដម ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី សមាជិក
៣_តំណាងក្រសួងផែនការ « ថ្នាក់នាយកដ្ឋាន » សមាជិក
៤_តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ « ថ្នាក់នាយកដ្ឋាន » សមាជិក
៥_តំណាងក្រសួងពាណិជ្ជកម្ម « ថ្នាក់នាយកដ្ឋាន » សមាជិក
៦_តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន « ថ្នាក់នាយកដ្ឋាន » សមាជិក
៧_តំណាងក្រសួងអប់រំយុវជន និង កីឡា « ថ្នាក់នាយកដ្ឋាន » សមាជិក
៨_តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
៩_តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ« ថ្នាក់នាយកដ្ឋាន »សមាជិក
១០_តំណាងធនាគារជាតិ «ថ្នាក់នាយកដ្ឋាន » សមាជិក
១១_តំណាងក្រសួងឧស្សាហកម្មរ៉ែនិងថាមពល « ថ្នាក់នាយកដ្ឋាន » សមាជិក
១២_តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍« ថ្នាក់នាយកដ្ឋាន »សមាជិក
១៣_តំណាងក្រសួងទេសចរណ៍ « ថ្នាក់នាយកដ្ឋាន » សមាជិក
១៤_តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី « ថ្នាក់នាយកដ្ឋាន » សមាជិក
១៥_តំណាងក្រសួងការពារជាតិ « ថ្នាក់នាយកដ្ឋាន » សមាជិក
១៦_តំណាងក្រសួង[illegible] « ថ្នាក់នាយកដ្ឋាន » សមាជិក
១៧_តំណាងក្រសួ[illegible] [illegible]ដ្ឋាន » [illegible]

១៨_មន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ « លេខាធិការ »

ប្រការ ២: គណៈកម្មការចំរុះកម្ពុជា_ម៉ាឡេស៊ី មានភារកិច្ចដូចតទៅ :

_ជំនួយការអោយរាជរដ្ឋាភិបាល លើការងារសហប្រតិបត្តិការសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស

សំរបសំរួលជាមួយបណ្តាក្រសួង ស្ថាប័នដែលពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការកម្ពុជា ម៉ាឡេស៊ី

_ពិភាក្សារៀបចំគំរោងការងារ ដែលមានលទ្ធភាពធ្វើសហប្រតិបត្តិការទៅតាមវិស័យនីមួយ ៗ

_ជំរុញការអនុវត្តន៍កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ

_ត្រួតពិនិត្យការអនុវត្តន៍កិច្ចសហប្រតិបត្តិការដែលភាគីទាំងពីរបានព្រមព្រៀងគ្នា

_ពិនិត្យសិក្សាកុលមតិ និង លើកវិធានការលើរាល់ឯកសារពាក់ព័ន្ធដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច

_ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលតាមកាលកំណត់

ប្រការ ៣ : គណៈកម្មការចំរុះកម្ពុជា_ម៉ាឡេស៊ី មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ ឬតំណាងក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការងារសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ដើម្បីចូលរួមបំពេញការងារតាមការជាក់ស្តែង ។

ប្រការ ៤: សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំនិងធ្វើការងារតាមសេចក្តីអញ្ជើញ និង ការណែនាំរបស់ប្រធាន ។

ប្រការ ៥: គណៈកម្មការចំរុះកម្ពុជា_ម៉ាឡេស៊ី មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជាផ្លូវការ ។

ប្រការ ៦: សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិកម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្រុមប្រឹក្សា

អភិវឌ្ឍន៍កម្ពុជា និងរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវសហការអនុវត្តសេចក្ដីសំរេចនេះអោយ មានប្រសិទ្ធភាពពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្ថលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

III- ការងារបណ្ដាក្រសួង

១—ទីស្ដីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៤៩/៩៥ ពម.ប្រក

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសាន្ត បញ្ញត្តិមាត្រា ទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារព័ត៌មានត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជា អនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ មេសា ១៩៩២ នីតិកាលទី ១
- បានឃើញលិខិតស្នើសុំរបស់លោក សោរ សុខខុន ប្រធានក្រុមប្រឹក្សាភិបាលអាណត្តិទី ២ នៃសមាគមបត្រព័ត៌មានកម្ពុជា លេខ ១៦ សគក/៩៥ ចុះថ្ងៃទី ២១ មិថុនា ១៩៩៥

សម្រេច

ប្រការ ១ : យល់ព្រមតាមសំណើអោយប្ដូរតំណែងពីលោក **អ៊ុន ម៉ន** អតីតចាងហ្វាងទស្សនាវដ្ដីសមាគមគ្រូពេទ្យកម្ពុជា ដែលបានសុំលាឈប់ពីតំណែង ជូនមកលោក **សៅ សុខខុន** ជាចាងហ្វាង ទស្សនាវដ្ដីសមាគមគ្រូពេទ្យកម្ពុជាវិញ ។

ប្រការ ២ : ខ្លឹមសារអត្ថបទនិងសកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកកាសែតនិងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និងស្នើប្រគល់ទស្សនាវដ្ដីចំនួន ១៥ ច្បាប់រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤: លោកចាងហ្វាងការផ្សាយទស្សនាវដ្ដីសមាគមគ្រូពេទ្យកម្ពុជា និងនាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥: ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥០/៩៥ ពម.ប្រក

ស្ដីពីការផ្លាស់ប្ដូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

* * *

- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម **សីហនុ** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- យោងសំណើលេខ ៥៤៤ អសរប ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ពិនិត្យតម្រូវការចាំបាច់របស់អគ្គលេខាធិការដ្ឋានរដ្ឋសភា

សំរេច

ប្រការ ១ : យល់ព្រមជូនលោក **អ៊ិច - សំអុល** បុគ្គលិកទីភ្នាក់ងារសារពត៌មានខ្មែរនៃក្រសួងពត៌មាន និង ក្របខ័ណ្ឌមួយកន្លែងផ្លាស់ទៅបំរើការងារនៅអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

ប្រការ ២ : ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន ទីភ្នាក់ងារសារពត៌មានខ្មែរត្រូវសំរួលផ្ទេរប្រាក់បៀវត្សជូនអគ្គលេខាធិការដ្ឋានរដ្ឋសភាជាក្រោយ ។

ប្រការ ៣ : ទីភ្នាក់ងារសារពត៌មានខ្មែរ នាយកដ្ឋានបុគ្គលិក និង រដ្ឋបាល នាយកដ្ឋានផែនការគណនេយ្យហិរញ្ញវត្ថុ និង សាមីខ្លួន មានកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥១/៩៥ ពម.ប្រក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការពីក្របខ័ណ្ឌ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យលើសំណើលេខ ០៧៦ បល/៩៥ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៥ របស់អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា
- ពិនិត្យលើសំណើសុំឈប់បំរើការងាររបស់សាមីខ្លួន

សំរេច

ប្រការ ១: លុបឈ្មោះអ្នកស្រី **លី សុគាន** ចេញពីបញ្ជីក្របខ័ណ្ឌអគ្គនាយកដ្ឋានវិទ្យុជាតិ នៃក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ នេះទៅដោយសាមីខ្លួន

ស្ម័គ្រចិត្តសុំឈប់ ។

ប្រការ ២: ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន ត្រូវបានទទួលប្រាក់ឧបត្ថម្ភម្តងគត់ដោយស្មើនិងប្រាក់បៀវត្សដូចខាងក្រោម :

២៤.៩៦០៖០០ គុណ ៣ = ៧៤.៨៨០៖០០

ប្រការ ៣: អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នាយកដ្ឋានផែនការ គណនេយ្យ នាយកដ្ឋានបុគ្គលិក និងរដ្ឋបាលនិងសាមីខ្លួន មានភារកិច្ចអនុវត្តតាមប្រកាស ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥២/៩៥ ពម.ប្រក
ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង

* * *

- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យ ស្តីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩២
- បានឃើញសារាចរលេខ ០១ សរ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពី ការរាប់មន្ត្រីរាជការទូទាំងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យលើសកម្មភាពជាក់ស្តែងរបស់សាមីខ្លួន

សំរេច

ប្រការ ១: លុបឈ្មោះលោក **ខួន សុខកាល** ជាបុគ្គលិកចេញពីក្របខ័ណ្ឌអគ្គនាយកដ្ឋានវិទ្យុជាតិនៃក្រសួងព័ត៌មាន ។

ប្រការ ២: ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេង ៗ របស់សាមីខ្លួន ត្រូវផ្តាច់ចេញពីតារាងបើកប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានវិទ្យុជាតិ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥

ប្រការ ៣: អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នាយកដ្ឋានបុគ្គលិកវិជ្ជាជីវៈ នាយកដ្ឋានគណនេយ្យ ផែនការហិរញ្ញកិច្ច និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៣/៩៥ ព.ម.ប្រក.

ស្តីពីការយល់ព្រមមន្ត្រីរាជការតាំងស៊ប់ក្នុងក្របខ័ណ្ឌ

* * *

- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការអោយប្រើប្រាស់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- យោងសេចក្តីសំរេចលេខ ០៧.៩៤ សសរ.មសក្រខ. ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៤ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងសេចក្តីសំរេចលេខ ០០៨.៩៤ ពម.សរ.ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៤ របស់ក្រសួង ពត៌មាន ស្តីពីការបែងចែក [illegible] ទៅតាមអង្គភាពនីមួយៗ

សម្រេច

ប្រការ ១ : យល់ព្រមអោយតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនអ្នកស្រី **នាង ជួនផា** [illegible] ថ្នាក់ឧត្តម បច្ចុប្បន្ន ជាបុគ្គលិកនៅអគ្គនាយកដ្ឋាន ទូរទស្សន៍ [illegible]

ក្នុងប្រភេទ ខ.១ : ៣២.១០០៛ តាម គោលការណ៍ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបានទទួលប្រាក់បៀវត្ស ១០០% ចាប់ពី ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ នេះតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋាន ទូរទស្សន៍ នាយកដ្ឋាន បុគ្គលិក និង រដ្ឋបាល នាយកដ្ឋានផែនការ ហិរញ្ញវត្ថុ និង សាមីខ្លួន មានភារៈអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៤/៩៥ ព.ម.ប្រ.ក.

ស្តីពីការយល់ព្រម និង ទទួលស្គាល់មន្ត្រី រាជការ

* * *

- បានឃើញព្រះរាជក្រឹត្យព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងប្រកាសលេខ ១១៧ ប្រ.ក.វ.វ.ស.ប ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៥ របស់ក្រសួង វប្បធម៌ វិចិត្រសិល្បៈ
- ពិនិត្យលើតម្រូវការនៃការងារចាំបាច់

សម្រេច

ប្រការ ១ : យល់ព្រម និង ទទួលស្គាល់លោក ជួន រិទ្ធី [illegible]នាយកដ្ឋាន [illegible] វប្បធម៌ នៃក្រសួង វប្បធម៌ និង វិចិត្រ[illegible] [illegible]បំពេញការងារនៅនាយក ដ្ឋានរដ្ឋបាល នៃក្រសួងពត៌[illegible] ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់[illegible] ។ ត្រូវបានទទួល[illegible]ពីស្ថាប័នរដ្ឋមន្ត្រីក្រសួង ពត៌មាន[illegible] និង [illegible]

ពត៌មាន ។

ប្រការ ៣ : នាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ, នាយកដ្ឋានបុគ្គលិក និង រដ្ឋបាល និង សាមីខ្លួនមានភារៈអនុវត្តតាមប្រកាស ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៥/៩៥ ព.ម.ប្រក.

ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង

* * *

- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យ ស្តីពីការកែលំអបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩២
- យោងតាមសំណើសុំលុបឈ្មោះរបស់អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជា លេខ ០៦៩ ប.ឈ.ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥
- ពិនិត្យលើសំណូមពររបស់សាមីខ្លួន

សម្រេច

ប្រការ ១ : លុបឈ្មោះលោក ខា ឌុល បុគ្គលិកបច្ចេកទេសផ្សាយ បានចូលបំរើការងារពីថ្ងៃទី ២៣-១០-៨៣ ដល់ ២១-០៨-៩៥ ចេញពីក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋាន វិទ្យុជាតិកម្ពុជានៃក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ តទៅ ។

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវបានទទួលម្តងគត់ គឺស្មើនឹងប្រាក់បៀវត្ស សរុបក្នុងខែ គុណនិងចំនួនឆ្នាំបានបំរើការងារ ដែលមានដូចខាងក្រោមនេះ ÷

លោក ខា ឌុល : ៤០.៨២០៛ × ១០ = ៤០៨.២០០៛០០

ប្រការ ៣ : អគ្គនាយកដ្ឋានវិទ្យុជាតិ នាយកដ្ឋានបុគ្គលិក រដ្ឋបាល នាយកដ្ឋានគណនេយ្យ ផែនការ ហិរញ្ញវត្ថុ និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៦/៩៥ ព.ម.ប្រ.ក
ស្ដីពីការលុបឈ្មោះ មន្ត្រី រាជការ

* * *

- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា ចុះ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០៥ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩២ ស្ដីពីការកែលំអរបៀបរដ្ឋកម្មា ភិបាល បុគ្គលិក កម្មករដ្ឋ
- យោងតាមសំណើសុំលុបឈ្មោះរបស់អគ្គនាយកដ្ឋាន ទូរទស្សន៍ជាតិកម្ពុជា លេខ ០១ ទ.ទ.ក. ជ.ក. ចុះថ្ងៃទី ០៣–០១–៩៥
- យោងតាមសំណើសុំឈប់របស់ សាមីខ្លួនទាំងពីរនាក់

សម្រេច

ប្រការ ១ : លុបឈ្មោះ មន្ត្រី រាជការចំនួន ០២ នាក់ ចេញពីក្របខ័ណ្ឌអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៃ ក្រសួងពត៌មាន ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ១៩៩៥ តទៅដូចជា ÷

១–លោក ឡាំ សំណា បុគ្គលិក ចូលបំរើការងារ : ១១–០៧–៨៥

២–លោក ត្រាំ ខឿ បុគ្គលិក ចូលបំរើការងារ : ១៥–០៤–៧៩

ប្រការ ២ . ប្រាក់ឧបត្ថម្ភរបស់សាមីខ្លួន ត្រូវបានទទួលម្តងគត់ពីស្មើនឹងប្រាក់បៀវត្សសរុបប្រចាំខែ តុលា និង ចំនួនឆ្នាំដែលបំរើការងារ មានដូចខាងក្រោមនេះ :

១-លោក ឡៅ **ស៊ិណា** : ៣០.៨១០៛ × ១០ = ៣០៨.១០០៛០០

២-លោក ឡើ **ឆឿ** : ៣០.៨១០៛ × ១០ = ៣០៨.១០០៛០០

ប្រការ ៣ : អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នាយកដ្ឋានរដ្ឋបាល បុគ្គលិក នាយកដ្ឋានផែនការហិរញ្ញកិច្ច គណនេយ្យ និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

២-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥០០ ប្រក.មស.បល.

ស្តីពីការអនុញ្ញាតច្បាប់អោយផ្អាកការងារដោយគ្មានបៀវត្ស

* * *

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត.១០-៩៤៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល [illegible] រាជរដ្ឋាភិបាល
- បានឃើញសារាចរណែនាំលេខ ០៣ សរ. ចុះថ្ងៃទី ០៩-០៣-១៩៩៣ ស្តី

ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការអនុញ្ញាតអោយមន្ត្រីរាជការស៊ីវិលផ្អាកការងារមួយរយៈដោយគ្មានបៀវត្ស

- បានឃើញពាក្យស្នើសុំរបស់សាមីខ្លួន ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **យស់ សត្ថា** ផ្អាកការងារដោយគ្មានបៀវត្សរយៈពេលប្រាំមួយខែបន្តទៀត ដោយគិត ចាប់ពីថ្ងៃទី ០១-០៧-៩៥ ដល់ថ្ងៃទី ០១-០១-១៩៩៦ ។

ប្រការ ២ : ក្របខ័ណ្ឌលោក **យស់ សត្ថា** ត្រូវរក្សាទុកក្នុងអង្គភាពរបស់សាមីខ្លួនដដែល ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានបៀវត្ស នាយកដ្ឋានក្របខ័ណ្ឌ និង សាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ទ្រាក់ សុខ

* * *

៣–អាជ្ញាធរអាកាសចរស៊ីវិល

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្តីប្រកាសលេខ ០៦៧៨ អ.អ.ព.ក.៩៥

* * *

- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ. ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា
- ផ្អែកតាមសេចក្តីកំណត់លេខ ០៥២ អ.អ.ស.ព.ក/៩៤ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការប្រើប្រាស់ប័ណ្ណ និង ផ្អាករថយន្តចេញចូលអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ប្រចាំឆ្នាំ ១៩៩៥
- ពិនិត្យលើការផ្តល់ប័ណ្ណចេញ ចូលកន្លងមករបស់អាជ្ញាធរអាកាសចរស៊ីវិល

ចំពោះស្ថាប័នរដ្ឋ អគ្គរដ្ឋទូត ក្រុមហ៊ុនអាកាសចរ ក្រុមហ៊ុនវិនិយោគទុនកន្លងមក

– ដើម្បីរក្សាសុវត្ថិភាពការធ្វើដំណើរទៅមករបស់ភ្ញៀវក្នុងអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង

ប្រកាស

១– ឈប់ផ្តល់ប័ណ្ណ និង ផ្លាករថយន្តសំរាប់ចេញ ចូលក្នុងអាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ចាប់ពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥ នេះតទៅ ។

២– ប័ណ្ណចេញចូល និង ផ្លាករថយន្តដែលបានផ្តល់កន្លងមកនៅមានប្រសិទ្ធភាពប្រើប្រាស់រហូតដល់មានសេចក្តីប្រកាសជាថ្មី ។

៣–អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង និង ស្ថាប័ន ចំណុះរដ្ឋបាលអាកាសចរស៊ីវិល ព្រមទាំង ស្ថាប័នរដ្ឋ, អង្គការបរទេស, ក្រុមហ៊ុន អាកាសចរ, ក្រុមហ៊ុនឯកជនទាំងអស់មេត្តាអនុវត្ត និង ព្រាបតាមការគួរ ។

អគ្គនាយក

ហត្ថលេខា និង ត្រា

កែវ សាវល

* * *

៤– នីតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាសលេខ ៥១៩ បល.ប្រក

ស្តីការបង្កើតអង្គភាពឧម្ពន់ និង ខ្វាស់ខ្វាល់

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥១៩ បល.ប្រក.

* * *

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**

ចន្លោះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- លិខិតលេខ ២៤៦ សជណ.ពហ. ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩២ របស់ ខុទ្ទកាល័យក្រុម ប្រឹក្សារដ្ឋមន្ត្រី ស្តីពីការងារគ្រប់គ្រងទម្ងន់ និង រង្វាស់រង្វាល និង ការត្រួតពិនិត្យគុណភាពផលិតផលផលិតកម្ម

សម្រេច

ប្រការ ១ : បង្កើតអង្គភាពទម្ងន់ និង រង្វាស់រង្វាល់ស្ថិតក្នុងនាយកដ្ឋានបច្ចេកទេសក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីដំណើរការគ្រប់គ្រងផ្នែកទម្ងន់ និងរង្វាស់ រង្វាល់ ។

ប្រការ ២ : អង្គភាពទម្ងន់ និង រង្វាស់រង្វាល់ មានភារកិច្ច និង សិទ្ធិអំណាចដូចតទៅ ÷

ក–ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍ទម្ងន់ និង រង្វាស់រង្វាល់ដែលប្រើក្នុងសកម្មភាព អាជីវកម្ម នៃ ព្រះរាជាណាចក្រកម្ពុជា ។

ខ–មានវិធានការកែតម្រូវ បង្ការ បទល្មើសពីការប្រើប្រាស់ឧបករណ៍ទម្ងន់ និង រង្វាស់រង្វាល់ព្រម ទាំងបទល្មើសពីការបន្លំបរិមាណនៃទំនិញ ។

គ–ធ្វើកោសល្យវិច័យក្នុងសមត្ថកិច្ចរបស់ខ្លួន តាមសេចក្តីស្នើសុំពីតុលាការ ។

ឃ–ត្រួតពិនិត្យមូលដ្ឋានផលិត រោងជាងជួសជុល ឧបករណ៍ទម្ងន់ និង រង្វាស់ រង្វាល់ ។

ប្រការ ៣ : អង្គភាពទម្ងន់ និង រង្វាស់រង្វាល់ ត្រូវគ្រប់គ្រងដោយប្រធានមួយរូប អនុប្រធាន មួយចំនួន និង មានក្រុមការងារជំនាញមួយចំនួនតាមការចាំបាច ។

ប្រការ ៤ : អង្គភាពនេះ មានអត្ថិភាពរៀបចំ និង អនុវត្តការងាររបស់ខ្លួនរហូតដល់មានការ សំរេចជាថ្មី ។

ប្រការ ៥ : នាយកខុទ្ទកាល័យ ប្រធានមន្ទីរ គ្រប់ប្រធាននាយកដ្ឋាន ប្រធានគណកម្មាធិការត្រួត ពិនិត្យត្រូវអនុវត្ត នូវប្រកាសនេះតាមមុខការរៀងៗ ខ្លួន ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

ប្រកាសលេខ ៥២០ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក ចេង សេ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៣១៧៥ ក.ព ចុះថ្ងៃទី ២៦–៣–៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិកំពង់បាយខាងជើង ឃុំ កំពង់បាយ ស្រុក កំពង់បាយ ខេត្ត កំពត បើកដំណើរការសិប្បកម្មផលិតទឹកត្រីកំពត « ជួរ–ហ៊្វត » នៅក្នុងទីតាំងអណ្តូងខ្មែរ ឃុំ អណ្តូងខ្មែរ ស្រុក កំពង់បាយ ខេត្តកំពត ។

ប្រការ ២ : លោក ចេង ស ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលទឹកត្រីកំពត សញ្ញា « ចង្កូត » ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណាងឡើង ។

* * *

ប្រកាសលេខ ៥៣៣ ឧក.ប្រក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយសិប្បកម្មផលិតស្រាស សញ្ញា «ព្រះអាទិត្យ» ដែលមានលោក សៀន ផារ៉ូ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៣៨៤២២ ក.ណ ចុះថ្ងៃទី ១៤–១២–៩០ ជាប្រធានអាស័យដ្ឋានបច្ចុប្បន្ន ភូមិ ដូង ឃុំ ព្រែកញ្ញៅ ស្រុក ពញាឮ ខេត្ត កណ្តាល បើកដំណើរការផលិតកម្មនៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក សៀន ផារ៉ូ ត្រូវបានអនុញ្ញាតអោយផលិតស្រាស សញ្ញា «ព្រះអាទិត្យ» ស្របតាមគំរូសញ្ញាសំគាល់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាត បន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬ បង្ក.

អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើង ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ឡូ សុធីរ:

* * *

៥—ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សេចក្ដីសម្រេច

ភ្នំពេញ,ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្ដីសម្រេចលេខ ៣៥៦ សសរ.កសក

ស្ដីពីការស្រាវជ្រាវចំពោះជនសង្ស័យកូនត្រីប្រាខ្មៅ

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ៩៤–៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ របស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើរបស់នាយដ្ឋានជលផល

សំរេច

ប្រការ ១ : អនុញ្ញាតពិសេសអោយនាយកដ្ឋានផលផល សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ អនុវត្តស្រាវជ្រាវពិសោធន៍ស្ទូចកូនត្រីប្រាខ្មៅក្នុងរដូវឆ្នាំ ១៩៩៥ ។

ប្រការ ២ : អនុញ្ញាតអោយឈ្មោះ **សេខ ខួន** សហការអនុវត្តស្រាវជ្រាវពិសោធន៍ស្ទូចកូនត្រីប្រាខ្មៅស្ថិតនៅចំណុចចាប់ពីអើមត ខាងកើតហាងសាំងឫស្សីកែវ ទៅទល់នឹងព្រំប្រទល់ស្រុកពញាឮ ក្នុងខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានគណនេយ្យ–ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការស្ថិតិប្រធាន គណៈកម្មការត្រួតពិនិត្យ ប្រធាននាយកដ្ឋានផលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេច នេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឈា សុខ

* * *

៦–ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ៧ ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៣០ ប្រកវវស.ម

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ

មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តស្ទឹងត្រែង

រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា, ឆ្នាំ

១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

_យោងតាមសំណើសុំផ្ទេរ លោក សឿន ហេន ប្រធានការិយាល័យរដ្ឋបាល នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ស្ទឹងត្រែង ។

_យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង អភិវឌ្ឍន៍ជនបទ ចុះថ្ងៃទី ០២–៣–៩៥ ។

_យោងតាមចំណារយល់ព្រមពីថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ១១–៧–៩៥ ។

សំរេច

មាត្រា ១ : លោក **សឿន ហេន** ប្រធានការិយាល័យរដ្ឋបាល នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ស្ទឹងត្រែង ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំពេញការងារនៅមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ស្ទឹងត្រែង ។

មាត្រា ២ : មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត ស្ទឹងត្រែង ត្រូវផ្ទេរប្រាក់បៀវត្សរបបឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួន និងក្របខ័ណ្ឌមួយកន្លែងជូនមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ស្ទឹងត្រែង ។

មាត្រា ៣ : នាយកដ្ឋានបុគ្គលិក និងកិច្ចការសង្គម នាយកដ្ឋានផែនការគណនេយ្យ និងហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តស្ទឹងត្រែង ព្រមទាំងលោក **សឿន ហេន** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាំង

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៣២ ប្រក.វចស.ម

ស្តីពីការបង្កើតគណៈកម្មការ និងអនុគណៈកម្មការ

ប្រឡងបរិញ្ញាបត្រ សិល្បៈតន្ត្រី ឆ្នាំ ១៩៩៤–៩៥

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– តាមសំណើរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

សំរេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មការ និងអនុគណៈកម្មការនានាសំរាប់ដំណើរការប្រឡងយកបរិញ្ញាប័ត្រសិល្បៈតន្ត្រីសំរាប់ឆ្នាំសិក្សា ១៩៩៤–៩៥ ដែលមានសមាសភាពដូចតទៅ :

គណៈកម្មការមេប្រយោគ

១_អ្នកអង្គម្ចាស់	**ស៊ីសុវត្ថិ ស៊ីរីវុឌ្ឍឃ៉ីណារ៉ា**	រដ្ឋលេខាធិការ	ប្រធាន
២_លោក	**ឌុយ គៀន**	ប្រតិភូទទួលខុសត្រូវសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	អនុប្រធាន
៣_លោក	**អ៊ុំ មង្គល**	ទីប្រឹក្សា ឯកឧត្តមរដ្ឋមន្ត្រី	សមាជិក
៤_លោក	**ឃួន ថន**	អគ្គនាយករងបច្ចេកទេស	សមាជិក
៥_លោក	**ហាឡូ សុត**	ប្រធាននាយកដ្ឋានសិល្បៈ និងទស្សនីយភាព	សមាជិក
៦_លោក	**អ៊ុក សុជាតិ**	អនុប្រធាននាយកដ្ឋានបុគ្គលិក	សមាជិក
៧_លោក	**ឡោ សាន**	សាកលវិទ្យាធិការរង	សមាជិក
៨_លោក	**ម៉ែន ផារ៉ត**	ព្រឹទ្ធបុរសមហាវិទ្យាល័យតន្ត្រី	សមាជិក
៩_លោក	**ម៉ៅ គៀង**		សមាជិក
១០_លោក	**គង់ គន្ធា**		សមាជិក

អនុគណៈកម្មការលេខាធិការដ្ឋាន និងអនុរក្ស

១_លោក	**ញ៉ឹម សារឿន**	ប្រធាន
២_លោក	**ម៉ាន់ ពុទ្ធសេរី**	សមាជិក
៣_កញ្ញា	**ចាន់ គីមហេង**	សមាជិក
៤_លោក	**សុខ ឌុល**	សមាជិក

៥_កញ្ញា **តី លក្ខិណា** សមាជិក

៦_កញ្ញា **ស៊ី ស៊ុថា** សមាជិក

៧_លោក **ឆោម សេរីវុធ** សមាជិក

អនុគណៈកម្មការកំណែទម្រង់វិជ្ជាសា

១_លោក **គង់ គន្ធា** សោភ័ណវិជ្ជាតន្ត្រី

២_លោក **យស់ ចំនួនតារា** ចរិតឧបករណ៍តន្ត្រី

៣_អ្នកស្រី **ណេព គន្ធារ៉េត** ប្រវត្តិតន្ត្រីសាកល

មាត្រា ២ : ប្រធានគណៈកម្មការ មេប្រយោគមានសិទ្ធិអញ្ជើញ សមាជិក និងបណ្ដាអនុគណៈកម្មការប្រជុំដើម្បីរៀបចំវិធីសាស្ត្រ ដំណើរការប្រឡងអោយមានប្រសិទ្ធភាព ។

មាត្រា ៣ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានបច្ចេកទេស សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់ចប់ភារកិច្ច ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

នុត ណារ៉ាង

* * *

៧—នីស្ដីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ប្រកាស

ភ្នំពេញ, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៥៩៣ អ.ជ.ប

«ស្ដីពីការផ្ទេរបុគ្គលិក—មន្ត្រីរាជការ»

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

បានឃើញ : -រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការប្រព្រឹត្តទៅនៃក្រសួងអភិវឌ្ឍន៍ជនបទ
-លិខិតលេខ ៦៧៦ លស.បស ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីពីការយល់ព្រមទទួលលោក សូ នៅ

សំរេច

ប្រការ ១ : ផ្ទេរលោក **សូ នៅ** និងក្របខ័ណ្ឌ ១ កន្លែង បច្ចុប្បន្នជាប្រធានការិយាល័យឃោសនា-ផលិតឯកសារ នៅនាយកដ្ឋានបណ្ដុះបណ្ដាល និងស្រាវជ្រាវ នៃក្រសួងអភិវឌ្ឍន៍ជនបទអោយទៅបំរើការងារនៅទីស្ដីការគណៈរដ្ឋមន្ត្រី «នាយកដ្ឋានស៊ីហ្វោឌី»

ប្រការ ២ : ប្រាក់បៀវត្ស និងរបបគោលនយោបាយផ្សេងៗ អង្គភាពថ្មីមានភារកិច្ចផ្ដត់ផ្គង់បន្តបន្ទាប់ពីមានវិញ្ញាបនប័ត្រផ្ដាច់ប្រាក់បៀវត្សពីអង្គភាពចាស់

ប្រការ ៣ : ខុទ្ទកាល័យ-នាយកដ្ឋាន ហិរញ្ញកិច្ច-នាយកដ្ឋានបណ្ដុះបណ្ដាល និងស្រាវជ្រាវ និង សាមីជន ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
សំ ឝុន្ធី

* * *

៨-ទីស្ដីការក្រសួងធម្មការ និង សាសនា

សេចក្ដីសំរេច

ភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៥

សេចក្ដីសំរេចលេខ ១៤៨/៩៥ ក.ធ.ស

ស្ដីពីការអនុញ្ញាតច្បាប់ទទួលស្គាល់អោយបើក

កន្លែងថ្វាយបង្គំព្រះរបស់ក្រុមជំនុំគ្រីស្ទានខ្មែរ

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងទី ២ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញលិខិតស្នើសុំបើកកន្លែងថ្វាយបង្គំព្រះរបស់ក្រុមជំនុំគ្រីស្ទានខ្មែរបាទិស្ទ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើក ស្នាក់ការថ្វាយបង្គំរបស់ក្រុមជំនុំគ្រិស្ទានខ្មែរបាទិស្ទមួយកន្លែងស្ថិតនៅផ្លូវជាតិលេខ ១ ភូមិត្បៀនសាំង ឃុំស្វាយរៀង ស្រុកស្វាយរៀង ខេត្ត ស្វាយរៀង ។

ប្រការ ២ : ក្រុមជំនុំគ្រិស្ទានខ្មែរបាទិស្ទ ត្រូវអនុញ្ញាតអោយផ្សព្វផ្សាយនូវឯកសារផ្សេងៗ ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : ក្រុមជំនុំគ្រិស្ទានខ្មែរបាទិស្ទ ត្រូវគោរពអោយបានម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការ និងសាសនាសន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និងសណ្តាប់ធ្នាប់សង្គម។

ប្រការ ៤ : ក្រុមជំនុំគ្រិស្ទានខ្មែរបាទិស្ទ ត្រូវអនុវត្តន៍តាមសេចក្តីសំរេចនេះ រាល់ការអនុវត្តន៍ផ្ទុយពីសេចក្តីសំរេចខាងលើ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានការពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍សេចក្តីសំរេចខាងលើនេះអោយមានប្រសិទ្ធភាព ។

ប្រការ ៦ : សេចក្ដីសំរេចនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន ចណ្ណារ័ត្ន

* * *

